ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៦១ ...... សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការចំណាត់ថ្នាក់សម្រាប់វាយតម្លៃ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៤/៨៦១ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងមន្ត្រីរាជការ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៥៨ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការតម្លើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ និងតម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល
- ប្រកាសលេខ ៧១៥ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការចំណាត់ថ្នាក់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងវាយតម្លៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ២.-**

សមាសភាពគណៈកម្មការចំណាត់ថ្នាក់ក្រសួង រួមមាន÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ | អនុប្រធាន |
| ៣. លោក **ញ៉ៃម សុវណ្ណា** | អគ្គលេខាធិការរង | សមាជិក |
| ៤. លោក **ម៉ិត សច្ចារ** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥. លោកស្រី **ថោង វណ្ណសុជីវី** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦. លោក **ផន ផុន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. លោក **មួយ វណ្ណាហឿន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៨. លោក **សួស សេរីវឌ្ឍនា** | ប្រធានការិយាល័យបៀវត្ស | លេខាធិការ ។ |

**ប្រការ ៣.-**

គណៈកម្មការចំណាត់ថ្នាក់ក្រសួងមានភារកិច្ចដូចតទៅ÷

- ពិនិត្យព្រឹត្តិប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈនិងស្ថានភាពសេវាកម្មរបស់មន្ត្រីរាជការម្នាក់ៗ ដែលត្រូវស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិ
- រៀបចំតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការក្រសួងសម្រាប់ឆ្នាំនីមួយៗ
- កំណត់មធ្យមភាគនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗពីពិន្ទុ ០ ដល់ ពិន្ទុ ២០ និងស្រង់ឈ្មោះបេក្ខជនតាមលំដាប់លំដោយពិន្ទុ
- កំណត់ការចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ផ្អែកតាមចំនួនកន្លែងដែលមានសល់ និងត្រូវបានអនុញ្ញាត ផ្អែកតាមវេនជ្រើសរើស និង/ឬ វេនអតីតភាព
- រៀបចំបញ្ជីឈ្មោះមន្ត្រីរាជការដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងធ្វើរបាយការណ៍ដាក់ជូនប្រធានស្ថាប័នពិនិត្យសម្រេច ។

**ប្រការ ៤.-**

នាយកដ្ឋានបុគ្គលិកមានភារកិច្ចរៀបចំសំណុំឯកសារ និងទម្រង់បែបបទពាក់ព័ន្ធនឹងសំណើដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ដាក់ជូនគណៈកម្មការចំណាត់ថ្នាក់ក្រសួង ។

**ប្រការ ៥.-**

ប្រកាសលេខ ១៤១ សហវ.ប្រក.ប ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការចំណាត់ថ្នាក់សម្រាប់វាយតម្លៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ